ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

សាលាដំបូងខេត្តសៀមរាប
សាលក្រមរដ្ឋប្បវេណី
-លេខ ២៨ "ជ"/ ៣៤៤
-ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២
-សំណុំរឿងរដ្ឋប្បវេណីលេខ ៣៥០
ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០២២

បានទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ២ និង ៣០ នាទី រសៀល នៅសាលសវនាការ ខ ១ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៣៥០ ចុះថ្ងៃទី២២ ខែ សីហា ឆ្នាំ២០២២ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តសៀមរាប។

**ក្រឡាបញ្ជី**

-លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប។

-ដើមចោទ **ធនាគារ** [redacted] តំណាងដោយលោក [redacted] **តុច ហុក** អាសយដ្ឋានបច្ចុប្បន្ននៅអគារលេខ [redacted] ។

អ្នកតំណាងដោយអាណត្តិ: លោកស្រី [redacted] អាសយដ្ឋានបច្ចុប្បន្ននៅអគារ [redacted] ។

-សហសហចុងចម្លើយ៖

១. ឈ្មោះ [redacted] **ប៊ុសាយ** ភេទប្រុស កើតឆ្នាំ១៩៨៣ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

២. ឈ្មោះ [redacted] **ស្រី** ភេទស្រី កើតឆ្នាំ១៩៨២ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

អ្នកតំណាងដោយអាណត្តិ: លោកស្រី [redacted] អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

## I. **អង្គហេតុ និងចំណុចវិវាទ**

**១.**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ</u> ៖

១.១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **ប៊ុសាយ** និងឈ្មោះ [redacted] **ស្រី** រួមគ្នាសងប្រាក់ដើមមិនទាន់ទូទាត់សងរួចចំនួន **១២២,៧៦៤.២៩$** មកឱ្យដើមចោទ ។

១.២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] **ប៊ុសាយ** និងឈ្មោះ [redacted] **ស្រី** បង់អត្រាការប្រាក់ចំនួន **១១.៥%** ក្នុងមួយឆ្នាំលើប្រាក់ដើម **១២២,៧៦៤.២៩$** មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី**២៤ ខែមេសា ឆ្នាំ២០២០** រហូតមកដល់បានទូទាត់រួចរាល់ ។



Scanned with CamScanner

១.៣-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **ភេទប្រុស** និងឈ្មោះ [redacted] **ភេទស្រី** បង់សំណងខូចខាតអត្រាចំនួន **២៤%** ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១២២,៧៦៤.២៩$ គិតចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ រហូតមកដល់បានទូទាត់រួចរាល់ ។

១.៤ បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **ភេទប្រុស** និងឈ្មោះ [redacted] **ភេទស្រី** សងសំណងជំងឺចិត្តខាតពេលវេលាសម្របសម្រួល ថ្លៃសេវាកម្មច្បាប់ និងសេវាមេធាវី ចំនួន ១០០០០$ មកឲ្យដើមចោទ ។

១.៥.ប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្នលើចំណុច ១.១ ចំណុច ១.២ ចំណុច ១.៣ និងចំណុច ១.៤ ។

១.៦ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

## ២.ការពន្យល់ត្រួសៗអំពីរឿងក្ដី ÷

កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ សហចុងចម្លើយ បានដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់ទៅ **ធនាគារ** [redacted] ចំកាត់ មានចំនួនទឹកប្រាក់ **១៤០,០០០** (មួយរយសែសិបពាន់ដុល្លារអាមេរិក) សហចុងចម្លើយ បានដាក់ពាក្យសុំខ្ចីឥណទានមក **ធនាគារ** [redacted] និងបានអនុម័តផ្ដល់ឥណទានជូនសហចុងចម្លើយ មានលិខិតផ្ដល់ឥណទាន ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ រយៈពេលខ្ចីចំនួន១០៨ខែ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៧ ។ សហចុងចម្លើយបានព្រមព្រៀងគ្នាជាមួយនិង **ធនាគារ** [redacted] ចុះកិច្ចសន្យាខ្ចីប្រាក់ (ការបង្កើតហ៊ីប៉ូតែក) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់កម្ចីទំហំ **១៤០,០០០** (មួយរយសែសិបពាន់ដុល្លារអាមេរិក) អាត្រាការប្រាក់ចំនួន **១១.៥០%** ក្នុងមួយឆ្នាំ និងអាត្រាការប្រាក់ ចំពោះការបង់យឺតយ៉ាវចំនួន **២៤%** ក្នុងមួយឆ្នាំ មានរយៈពេល ១០៨ខែ ហើយសហចុងចម្លើយក៏បានយកព្រមចុះកិច្ចសន្យាខ្ចីបរិភោគ ដោយដាក់ហ៊ីប៉ូតែកនូវអចលនវត្ថុ ១កន្លែងមានក្បាលដី ២៩៥០ (១៧១០០២០៨-២៩៥០) ទីតាំងស្ថិតនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដើម្បីធានាបំណុលខាងលើ ។ អំឡុងពេលប្រើប្រាស់កម្ចី សហកូនបំណុលបានបង់ប្រាក់ដើម និងការប្រាក់ជូនដើមបណ្ដឹងបានតែ២១ខែគត់ បានបង់ប្រាក់ដើមចំនួន **១៧,២៣៥.៧១** (ដប់ប្រាំពីរពាន់ពីររយសាមសិបប្រាំដុល្លារអាមេរិក និងចិតសិបមួយសេនគត់) និងបង់ការប្រាក់ចំនួន **២៦,៥៨១.០០** (ម្ភៃប្រាំមួយពាន់ប្រាំរយប៉ែតសិបមួយដុល្លារអាមេរិក) សរុបទឹកប្រាក់ទាំងអស់ចំនួន **៤៣,៨១៦.៧១** (សែសិបបីពាន់ប្រាំបីរយដប់ប្រាំមួយដុល្លារអាមេរិក និងចិតសិបមួយសេន) ។ សហចុងចម្លើយមិនបានបង់តាមតារាងកាលវិភាគ ហើយបានឈប់បង់ប្រាក់ចាប់តាំងពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ មកដល់បច្ចុប្បន្ន ។ **ធនាគារ** [redacted] បានជូនដំណឹងទៅសហចុងចម្លើយជាញឹកញាប់ ប៉ុន្តែសហចុងចម្លើយពុំបានទូទាត់សងប្រាក់ណាមួយមកឲ្យដើមបណ្ដឹងឡើយ ។ ហេតុដូច្នេះទើប **ធនាគារ** [redacted] សុំប្ដឹងមកសាលាដំបូងខេត្តសៀរាប ដើម្បីអោយភាគីសហចុងចម្លើយសងប្រាក់ដើមសរុប **$១២២,៧៦៤.២៩** (មួយរយម្ភៃពីរពាន់ប្រាំពីររយហុកសិបបួនដុល្លារអាមេរិក និងម្ភៃប្រាំបួនសេន) ។

៣. អង្គហេតុដែលគ្មានចំណុចវិវាទ៖

-សហចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានខ្ចីប្រាក់ពីធនាគារ កម្ពុជា [redacted] ក្នុងអាត្រាការប្រាក់ ១១.៥០% (ដប់មួយក្បៀសប្រាំភាគរយ) ក្នុងមួយឆ្នាំ និងអាត្រាការប្រាក់យឺតយ៉ាវចំនួន ២៤% ក្នុងមួយឆ្នាំ ។

**៤. ចំណុចវិវាទ៖**

១.តើដើមចោទមានសិទ្ធិទាមទារប្រាក់ដើមចំនួន ១២២,៧៦៤.២៩$ ឬក៏ចំនួន ៨២.៨៨១$ ពីសហចុងចម្លើយបានដែលឬទេ ?

២.តើដើមចោទមានសិទ្ធិទាមទារសំណងជំងឺចិត្តចំនួន ១០.០០០$ ពីចុងចម្លើយបានដែលឬទេ ?

**៥. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ៖**

<u>ការអះអាងដោយដើមចោទ</u> ៖

នាងខ្ញុំ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖ ខ្ញុំសូមរក្សាការទាមទារដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ទុកជាបានការដដែល ដោយហេតុថាចុងចម្លើយពិតជាបានខ្ចីប្រាក់ពីធនាគារ កម្ពុជា [redacted] ពិតប្រាកដមែន ។

<u>ការអះអាងដោយសហសហចុងចម្លើយ</u>៖ ខ្ញុំពិតជាបានខ្ចីប្រាក់ពីធនាគារពិតប្រាកដមែន ដោយបានខ្ចីប្រាក់ចំនួន ១៤០០០០$ ដូចមានក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ។ ខ្ញុំបានសងប្រាក់ទៅធនាគារបានចំនួន ២៣ខែ ត្រឹមថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២០ ដូចនេះប្រាក់ដើមដែលខ្ញុំនៅជំពាក់ធនាគារមានចំនួន ៨២.៨៨១$ ។ ចំពោះការប្រាក់ ១១.៥% ក្នុងមួយឆ្នាំលើប្រាក់ដើមនៅសល់ និងការប្រាក់យឺតយ៉ាវចំនួន ២៤% ក្នុងមួយឆ្នាំលើប្រាក់ដើមនៅសល់ខ្លួនឯកភាពទទួលស្គាល់តាមការទាមទាររបស់ដើមចោទ រីឯប្រាក់ជម្ងឺចិត្តចំនួន ១០០០០$ ដែលខាងធនាគារទាមទារពីខ្ញុំ ខ្ញុំពុំមានលទ្ធភាពសងទេ ដោយហេតុថា នាងខ្ញុំកំពុងមានជំងឺមហារីកសុដន់ ជំងឺរលាកពោះវៀនធ្ងន់ធ្ងរ និងបាក់ឆ្អឹងជើង ។ ខ្ញុំសំណូមពរសុំពន្យារពេលសងប្រាក់ទៅខាងធនាគារ ។

នាងខ្ញុំ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ ៖ កូនក្តីរបស់នាងខ្ញុំបានទទួលស្គាល់ការទាមទារដូចមានក្នុងសេចក្តីថ្លែងការណ៍នេះ ។ ក្នុងនាមខ្ញុំជាអ្នកតំណាងដោយអាណត្តិស្នើសុំតុលាការច្រានចោលការទាមទារលើចំណុចសំណងជម្ងឺចិត្តចំនួន ១០០០០$ ។ មូលហេតុថា កូនក្តីរបស់នាងខ្ញុំមានជំងឺ។

## <u>សំអាងហេតុ</u>

**១. ស្តីពីចំណុចវិវាទ**

ផ្អែកភស្តុតាង តុលាការទទួលស្គាល់ថា សហចុងចម្លើយពិតជាបានជំពាក់ប្រាក់ពីធនាគារ កម្ពុជា អាស៊ី ចំកាត់ ប្រាកដមែន ដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់(ការបង្កើតហ៊ីប៉ូតែក) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ដូច្នេះដើមចោទមានសិទ្ធិទាមទារនូវ៖

-ប្រាក់ដើមនៅសល់ចំនួន ***$១២២,៧៦៤.២៩*** (មួយរយម្ភៃពីរពាន់ប្រាំពីររយហុកសិបបួនដុល្លាអាមេរិក និងម្ភៃប្រាំបួនសេន) ។

-ការប្រាក់ចំនួន ១១.៥% (ដប់មួយក្បៀសប្រាំភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមដែលនៅសល់ចំនួន $ ១២២,៧៦៤.២៩ គិតចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៧ ។



Scanned with CamScanner

-ការប្រាក់យឺតយ៉ាវចំនួន ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមដែលនៅសល់ចំនួន $ ១២២,៧៦៤.២៩ គិតចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ រហូតមកដល់ថ្ងៃសងគ្រប់ចំនួនពិតប្រាកដមែន ។ គប្បីតុលាការ ពិចារណានិងសម្រេចតាមការទាមទាររបស់ដើមចោទ ។

## ២.ការវិនិច្ឆ័យការទាមទារ

**២.១** ចំពោះការទាមទាររបស់ដើមចោទលើប្រាក់ដើមដែលនៅសល់ចំនួន $១២២,៧៦៤.២៩ (មួយរយម្ភៃពីរពាន់ប្រាំពីររយហុកសិបបួនដុល្លាអាមេរិក និងម្ភៃប្រាំបួនសេន) ដោយផ្អែកតាមកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ សហចុងចម្លើយបានទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់ដើមដែលនៅសល់ចំនួន ៨២.៨៨១$ (ប្រាំបីម៉ឺនពីរពាន់ប្រាំបីរយប៉ែតសិបមួយដុល្លា)អាមេរិក មិនមែន $១២២,៧៦៤.២៩ (មួយរយម្ភៃពីរពាន់ប្រាំពីររយហុកសិបបួនដុល្លាអាមេរិក និងម្ភៃប្រាំបួនសេន) ទេ តែតាមការពិនិត្យភស្តុតាងជាតារាងកាលវិភាគបង់ប្រាក់ អាចឱ្យតុលាការទទួលស្គាល់ថាសងចុងចម្លើយពិតជានៅសល់ប្រាក់ដើមចំនួន $១២២,៧៦៤.២៩ (មួយរយម្ភៃពីរពាន់ប្រាំពីររយហុកសិបបួនដុល្លាអាមេរិក និងម្ភៃប្រាំបួនសេន) ប្រាកដមែន ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ។

**២.២** ចំពោះការទាមទារ ខាតបង់ពេលវេលានិងជំងឺចិត្តចំនួន ១០០០០ $ (មួយម៉ឺនដុល្លា) ដុល្លាអាមេរិក ពីសហចុងចម្លើយ តុលាការ យល់ឃើញថា ការទាមទារនេះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថា តុលាការបានសម្រេច អំពីការប្រាក់ និងការប្រាក់ពិន័យយឺតយ៉ាវទៅឱ្យដើមចោទរួចហើយ គប្បីច្រានចោលការទាមទារនេះ។

## ៣. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហសហចុងចម្លើយ ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៤. ស្តីពីការប្រកាសអនុវត្តបណ្តោះអាសន្ន

ដើមចោទបានសុំទាមទារសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន តុលាការ យល់ឃើញថា សហសហចុងចម្លើយបានទទួលស្គាល់ការទាមទាររបស់ដើមចោទរួចហើយ ហេតុដូច្នេះ មានភាពចាំបាច់ដើម្បីធ្វើការ ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបានតែលើប្រាក់ដើមនៅសល់តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១- បង្គាប់ឱ្យសហចុងចម្លើយមាន៖ ឈ្មោះ [redacted] បូសាយ ភេទប្រុស កើតឆ្នាំ១៩៨៣ ជនជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] រស្មី ភេទស្រី កើតឆ្នាំ១៩៨២ អាសយដ្ឋាននៅភូមិ[redacted] រួមគ្នាសងប្រាក់ទៅឱ្យ ធនាគារ[redacted] នូវ៖

១.១ ប្រាក់ដើមដែលនៅសល់ចំនួន $១២២,៧៦៤.២៩ (មួយរយម្ភៃពីរពាន់ប្រាំពីររយហុកសិបបួនដុល្លាអាមេរិក និងម្ភៃប្រាំបួនសេន)



Scanned with CamScanner

១.២ ការប្រាក់ចំនួន ១១.៥% (ដប់មួយក្បៀសប្រាំភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមដែលនៅសល់ចំនួន $១២២,៧៦៤.២៩ គិតចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៧ ។

១.៣ ការប្រាក់យឺតយ៉ាវចំនួន ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមដែលនៅសល់ចំនួន $ ១២២,៧៦៤.២៩ គិតចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៧ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន ។

២.ច្រានចោលការទាមទារផ្សេងទៀតរបស់ដើមចោទ ។

៣.សាលក្រមនេះមានអានុភាព អនុវត្តជាបណ្ដោះអាសន្នបានលើប្រាក់ដើម ត្រង់ចំណុច ១.១ នៃសេចក្ដីសម្រេចខាងលើ ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២២ ។

គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រម ។

**ចៅក្រម**

ហត្ថលេខា និង ត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ព្រហស្បតិ៍ ១កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ពស២៥៦៦

សៀមរាប, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]